# សិលាចារឹកវត្តអង្គខ្វាវ K.៥៦០ ឬ K.៧៣៩

## ១- ព័ត៌មានទូទៅ

សិលាចារឹកនេះ រកឃើញនៅចម្ងាយប្រហែល ៥០០ ម៉ែត្រ ខាងកើតវត្តអង្គខ្វាវ ដែលក្នុងរបាយការណ៍ឆ្នាំ១៩២៣ សរសេរថាវត្តនេះស្ថិតក្នុងស្រុកបាទី ខេត្តតាកែវ ប៉ុន្តែបច្ចុប្បន្នទីតាំងនោះ ស្ថិតនៅក្នុង ភូមិកាប់នឹម ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ។ អ្នកស្រុកដំណាលថា ដោយសារនៅទីវត្តនេះ មានអង្គមួយដែលមានដើមខ្វាវដុះ ទើបហៅថាវត្តអង្គខ្វាវ ប៉ុន្តែក្រោយមកសម្តេចព្រះសង្ឃរាជ ជួន ណាត បានដាក់ឈ្មោះវត្តនេះបន្ថែមទៀតជា វត្តសិរីនិវេសន៍ ហៅវត្តអង្គខ្វាវ។

ជាធម្មតា ទីតាំងភាគច្រើន ដែលមានឈ្មោះហៅថា «អង្គ» ច្រើនតែជាបុរាណស្ថានដែលបន្សល់ទុកមកតាំងពីសម័យមុនអង្គរនិងអង្គរ។ ពាក្យ «អង្គ» នេះ នៅសម័យមុនអង្គរប្រើជា «អង្គណ» ឬ «អង្គន»[១]។ តាមព័ត៌មានក្នុងគេហទំព័រ https://cisark.mcfa.gov.kh បញ្ជាក់ថា វត្តនេះមានកសិន្ធុមួយ និងបំណែកផ្ទាំងថ្មស្រទាប់ឬថ្មថ្ងើមអណ្តើក ១ផ្ទាំង។

អត្ថបទចារឹកនេះ សិក្សាដោយលោក ហ្ស៊ក សេដែស ចំនួន ២ដង។ លើកទី១ គឺនៅឆ្នាំ១៩៤២ លោកបានចុះបញ្ជីសិលាចារឹកនេះ ដាក់លេខ K.៥៦០។ ១០ឆ្នាំជាងក្រោយមក គឺលើកទី២ នៅឆ្នាំ១៩៥២ លោកបានចុះបញ្ជីសិលាចារឹកនេះ ដាក់លេខ K.៧៣៩។ បញ្ហានេះបណ្តាលមកពី សិលាចារឹកនេះកាលពីផ្តិតសំណៅលើកទី១ នៅសល់រូបរាងល្អច្រើន ប៉ុន្តែក្រោយមក ទំនងជាមុនពេលយកមកសារមន្ទីរជាតិ នៅឆ្នាំ១៩៣២ សិលាចារឹកនេះបានបែកបាក់ជាពីរផ្នែកធំៗ និង១ផ្នែកទៀតនៅជ្រុងខាងលើផ្នែកខាងឆ្វេង បានបាត់បង់ទៅ។ ក្រោយពេលដែលបាក់នេះ យកមករក្សាទុកនៅសារមន្ទីរភ្នំពេញ គេបានផ្តិត និងផ្តល់ព័ត៌មានដល់លោក ថាសិលាចារឹកនេះមានប្រភពមកពីខ្វាវ ខេត្តបាទី។ ប្រហែលមកពីបញ្ហាបាក់បែក ដាក់ប្រភពល្មៀងគ្នា និងរយៈពេលយូរផង ទើបលោកពុំចាំ និងចុះលេខសម្គាល់ផ្សេងគ្នា ព្រមទាំងមានអំណានផ្សេងគ្នាដោយអន្ទើផង។

---

[១] សូមអានបន្ថែម៖ https://ams.com.kh/khmercivilization/detail/2675។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

អត្ថបទចារឹកនេះ ចារនៅលើផ្ទាំងស្រទាប់ឬថ្មថ្ងើមអណ្តើក មានចំនួន១៣បន្ទាត់ ដែលបន្ទាត់ទី១៣នោះ សឹករេចរឹល អានពុំដាច់ឡើយ។ អត្ថបទចារដោយប្រើអក្សរព្រាហ្មីកម្លាយខ្មែរបុរាណ សរសេរជាភាសាខ្មែរបុរាណសម័យមុនអង្គរ និងពុំមានចុះកាលបរិច្ឆេទទេ។ តាមលក្ខណៈតួអក្សរឬបុរាណលេខន៍ របស់សិលាចារឹក វាគួរតែស្ថិតនៅរវាង ស.វ.ទី៧និងទី៨ នៃគ.ស.។ ចំណែកឯអត្ថន័យនៃអត្ថបទចារឹកនេះ គឺជាតង្វាយវត្ថុផ្សេងៗ ខ្ញុំបម្រើស្រីប្រុស និងស្រែ ថ្វាយចំពោះព្រះគម្តែងអញមណីសិវៈ។

យើងសង្កេតឃើញមានបញ្ហាអំណានតួអក្សរ «ទ» «ដ» និងពាក្យ «ល្ពាំ» ដែលគួរតែពិនិត្យមើលនៅទីនេះ។ នៅក្នុងអំណានទាំងពីរលើករបស់លោក ហ្សឺក សេដែស គាត់បានអានពាក្យនៅខាងចុងបន្ទាត់ទី២ជា «ឃោទ»។ បើផ្អែកលើទម្រង់តួអក្សរ នៅសម័យមុនអង្គរ តួអក្សរ «ទ» និង «ដ» មានលក្ខណៈខុសគ្នាតែបន្តិចប៉ុណ្ណោះ នៅចុងខ្សែតួអក្សរផ្នែកខាងស្តាំខាងក្រោម។ ខ្សែតួអក្សរ «ទ» ទម្លាក់ចុះក្រោម ឯខ្សែតួអក្សរ «ដ» ទាញឡើងមកលើបន្តិច។ តាមតួអក្សរនៅលើសិលាចារឹក យើងអាចឃើញយ៉ាងច្បាស់ថា ខ្សែខាងចុងផ្នែកខាងក្រោមនៃតួអក្សរ ទាញឡើងមកលើ ដែលយើងអាចសម្គាល់បានយ៉ាងច្បាស់ថា ជាអក្សរ «ដ»។ ម្យ៉ាងវិញទៀត ទោះបីជាភាគច្រើន យើងឃើញពាក្យនេះនៅក្នុងសិលាចារឹកដទៃទៀត ទាំងសម័យមុនអង្គរនិងអង្គរ សរសេរជា «ឃោទ» ក្តី ក៏យើងឃើញមានសិលាចារឹកតិចតួចខ្លះទៀតសរសេរជា «ឃោដ» ដែរ ដូចជាសិលាចារឹកមេលប់ K.១២៤៧ ជាដើម[២]។ ពាក្យ «ឃោទ» នេះ លោកស្រីបណ្ឌិត ពៅ សាវរស ពន្យល់ថាមានប្រភពមកពីភាសាប្រាក្រឹតថា «ឃោឌ» ត្រូវនឹងពាក្យសំស្ក្រឹតថា «ឃោទ» មានន័យថា «សេះ»។

ចំពោះពាក្យ «ល្ពាំ» វិញ លោក សេដែស ពុំបានដឹងអត្ថន័យឡើយ ប៉ុន្តែលោកថា ពាក្យនេះលេចឡើងជាស្ថាននាមឈ្មោះស្រុកមួយ នៅអមោឃបុរ ក្នុងសិលាចារឹកនៅកោះកេរ K.១៨៣-៦។ យ៉ាងនេះក្តី យើងក៏ឃើញមានពាក្យនេះ នៅក្នុងសិលាចារឹកសម័យអង្គរ រកឃើញនៅវត្តព្រះឥន្ទ្រកោសិយ K.២៦៣ ផ្ទាំងឃ ដែលវាជាវត្ថុស្ថិតនៅក្នុងប្រភេទតង្វាយចូលោហៈ។ ដូច្នេះវាគួរតែជាប្រភេទចូលោហៈម្យ៉ាង។ ចំណែកឯលោកស្រី

---

[២] សូមអាន វង់ សុធារ៉ា ២០០៩។

បណ្ឌិត ពៅ សាវរស និងលោកបណ្ឌិត ឡុង សៀម វិញ ក៏ពុំបានពន្យល់ន័យពាក្យនេះដែរ ប៉ុន្តែលោក ហ្វីលីព ដេន្នើរ វិញ ពន្យល់ន័យពាក្យនេះថាជា អង្កាំ ឬខ្សែកអង្កាំ។

## ២- អត្ថបទដើមជាអក្សរខ្មែរទំនើប

១- អំនោយិបោញ៊្រវជ្រកេទអា(យ៑)តវ្រះកម្រតាង៑(អ)

២- [ញ៊្រ]មណិគិវល្កាំ១ក្វសិលង្គៅ១ចវាទនិហុំ១ក្ល្គលិ១ក្ងុំឃោដ[3]វា

៣- -ទវិ១វាអគតិ១វាត្គរ៑១វាក្មៅ១វាចិវៅ១វាត្រេង៑១វាបោយិ១វា

៤- -យិ១វាចោង៑១វាទ្វាទគី១វាព្រៀស្តចិ១វាចេង៑[4]១វាសា១វាហិតង្គ

៥- (វ១) វាករិតិ១គេ១០-៧ក្ងុំតកន្តៃយិអ្មេស្រេតបិ១កុស្រេតបិ១

៦- [កុ]-ត្យសិ១កុត្មេង៑១កុន្វំ១កុ(ដុង៑)១(កុ)--១កុត្គះ[5]១កោនិកុ១មេវ

៧- -១កុវង៑១កុយុលិ[6]១កោនិកុ១កុចេហ្វិកនិ១កោនិកុ(១)

៨- (កុ-)កទ្រ១កោនិកុ១(កុ)---១(កុ)ស្តៅ១កុសេង៑ទៃវ១កុកញ្ជេ[7]--

៩- --វ្យ[8]១កោនិកុ១សវាលវ្ទ្វគេ២០-១០-១ស្រេវ្នាកិស្រុកិ១--

១០- [[ស្រេ]]ត្រសេកិស្រេត្រវង៑អាវាសស្រេកុមារគិល[9]ស្រេ---

១១- --ស្រេកំលុង៑ត្នលិស្រេបាសិកន្ទោញ៊្រស្រេវ្នុរអំរោល[10]---

១២- --១០ក្របិន្ទ៑១តោង៑តំ១០ស្វាតំស្វិកិ១-----

១៣- (អត្ថបទដាច់)

---

[3] លោក សេដែស (១៩៤២ & ១៩៥៤) អានជា «ឃោទ»។

[4] លោក សេដែស (១៩៥៤) អានជា «ចេរ៑»។

[5] លោក សេដែស (១៩៥៤) អានជា «ត្គុះ»។

[6] លោក សេដែស (១៩៥៤) អានជា «យលិ»។

[7] លោក សេដែស (១៩៤២) អានជា «កញ្ជ»។

[8] លោក សេដែស (១៩៥៤) អានជា «វា»។

[9] លោក សេដែស (១៩៤២) អានជា «ក្រមារគិល» ប៉ុន្តែនៅឆ្នាំ១៩៥៤ លោកអានជា «កុមារគិល» វិញ។

[10] លោក សេដែស (១៩៥៤) អានជា «សុំរោលិ»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

## ៣- អត្ថបទប្រែសម្រួល

តង្វាយរបស់បោញវជ្រកេទថ្វាយចំពោះព្រះគម្តែងអញមណីសិវៈ (មាន) ល្ពាំ១ ក្វស់ស្ពាន់១ ចរាក្រអូប១ ជម្រុក១។ អ្នកបម្រើប្រុស (មាន) វា-ទវិ១ វាអគត១ វាត្គរ១ វាក្មៅ១ វាចិរៅ១ វាត្រេង១ វាបោយ១ វា-យ១ វាចោង១ វាទ្វាទគី១ វាប្រៀស្តច១ វាចេង១ វាសា១ វាហិតង្គរ១ វាករិត១ (សរុបអ្នកបម្រើប្រុស) ១៧នាក់។ អ្នកបម្រើស្រី (មាន) ម៉ែស្រឥប១ កុស្រឥប១ កុ-ត្យស១ កុត្មេង១ កុវ្នំ១ កុជុង១ កុត្កុះ១ កូនកុ១ មេវ-១ កុវង១ កុយុល១ កូនកុ១ កុចេហ្វកន១ កូនកុ១ កុ-ភទ្រ១ កូនកុ១ កុស្តៅ១ កុសេងទេវ១ កុកញ្ចេ-- កុ--វ្វា១ កូនកុ១ សរុបទាំងក្មេងចាស់ ៣១នាក់។ ស្រែញាក់ស្រុក១ ស្រែត្រសេក ស្រែត្រពាំងអាវាស ស្រែកុមារសិល ស្រែកំលុងថ្នល់ ស្រែបាសកន្ទោញ ស្រែផ្ទុរអំរោល--១០ ក្របី១នឹម ដូង១០ដើម ស្លា៤០០ដើម(១ស្ទឹក)-----។

## ៤- ពន្យល់ពាក្យ

| | |
|---|---|
| **កន្តែ** | មនុស្សស្រី ពាក្យសម្គាល់មនុស្សស្រី។ |
| **ឃោជ** | មនុស្សប្រុស។ |
| **វា** | ពាក្យសម្គាល់អ្នកបម្រើប្រុស នាសម័យមុនអង្គរ។ |
| **កុ** | ពាក្យសម្គាល់អ្នកបម្រើស្រី នាសម័យមុនអង្គរ។ |
| **បោញ** | ឋានន្តរនាមមន្ត្រី ឬព្រាហ្មណ៍សម័យមុនអង្គរ។ |
| **ក្វសិ** | (ធត្រ)ក្វស់ ឬថូក្វស់។ |
| **ទនិហ៊ុំ** | គ្រឿងក្រអូប។ |
| **លង្តៅ** | ស្ពាន់។ |
| **ក្ឝលិ** | ជម្រុក។ |
| **សវាលវ្ឫទ្ធ** | ក្មេងចាស់។ |
| **ទ្នំ** | នឹម។ |

អត្ថបទដោយៈ ហ៊ិន ឈុនតេង

| | |
|---|---|
| តេំ | ដើម។ |
| ត្នេំ | ខ្នាតឯកសារដើមឈើ។ |
| តោង៑ | ដូង។ |
| ស្រេ | ស្រែ។ |
| ត្នល៑ | ថ្នល់។ |
| កំលុង៑ | កំលុង ក្នុង។ |
| ញ្នាក៑ | ញ្ញាក់។ |

## បញ្ជីឯកសារ


Cœdès, George. (1942). Inscription de Vằt Aṅ Khàv. In *Inscription du Cambodge* (Vol. II, pp. 37-38). Paris: Editions de Boccard.

Cœdès, George. (1954). Inscription de Khàv. In *Inscription du Cambodge* (Vol. VI, p. 54). Paris: Editions de Boccard.

Jenner, P. N., (2009). *A dictionary of Pre-Angkorian Khmer*. Pacific linguistics, Research school of Pacific and Asian studies, the Australian national University.

Pou, S. (2005). Dictionnaire vieux khmer-français-anglais. *Dictionnaire vieux Khmer-Français-Anglais*, 1-734.

វង់ សុធារ៉ា, (២០០៩), សិលាចារឹកនៃប្រទេសកម្ពុជាសម័យមុនអង្គរ១, បោះពុម្ពផ្សាយលើកទី២, គ្រឹះស្ថានបោះពុម្ពអង្គរ

ហ៊ុន ឈុនតេង, (២០២១), ប្រភពពាក្យ "អង្គ" (ទួលអង្គ), AMS Khmer Civilization, https://ams.com.kh/khmercivilization/detail/2675

Website: https://cisark.mcfa.gov.kh/core/showsite.php?id=4560


អត្ថបទដោយៈ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព



n. 408 / K. 560

សំណៅផ្តិតសិលាចារឹកវត្តអង្គខ្ទាវ K.៥៦០ (រូបថត៖ EFEO & CISARK)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សិលាចារឹកវត្តអង្គខ្វាវ K.៩៦០ ថតនៅឆ្នាំ១៩៧០ (រូបថត៖ EFEO_ CAM19804-3)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សិលាចារឹកវត្តអង្គខ្ជាវ K.៩៦០ (រូបថត៖ CISARK)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



ព្រះវិហារវត្តអង្គខ្វាវ (រូបថត៖ CISARK)



បំណែកថ្មស្រទាប់ឬថ្មថ្ងើមអណ្ដើក (រូបថត៖ CISARK)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង